01083269

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 02 / 04 / 2015
ម៉ោង (Time/Heure): 14:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Sann Rada

002/19-09-2007-ECCC/TC
**E1/280**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

ថ្ងៃ ព្រហស្បតិ៍ ទី ១៩ ខែ មីនា ឆ្នាំ ២០១៥

**សវនាការលើភ័ស្តុតាង - ថ្ងៃ ២៦១**

រៀបចំដោយ៖ **ជា ស៊ីវហ៊ាង** និង **Maddalena GHEZZI**

| **កំណត់ហេតុអ្នកចូលរួម** |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យ៉ា សុខន, ចៅក្រម Claudia FENZ, ចៅក្រម យូ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី, ចៅក្រម Martin KAROPKIN |
| ក្រឡាបញ្ជី៖ កញ្ញា ជា ស៊ីវហ៊ាង, លោក Maddalena GHEZZI |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក សេង លាង, លោក Dale LYSAK, កញ្ញា សុង ឆវ័ន្ត |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួន), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Victor KOPPE, លោក សួន វិសាល |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោក Arthur VERCKEN |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី Marie GUIRAUD, លោក ឡោ ជុនធី, លោកស្រី ទី ស្រីនណា, លោក វ៉ែន ពៅ, លោកស្រី ស៊ិន សុវន, លោក ហុង គីមសួន |

| |
|---|
| សាក្សី/ដើមបណ្ដឹង៖ លោក រៀល សន (2-TCW-860), លោក ឌុច ផារី (មេធាវីប្រឹក្សា) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ, លោកស្រី សួសុទ្ធារី |
| ផ្សេងៗ៖ កញ្ញា សុក សុភ័គមណីកា, កញ្ញា ស្រី ណាក់, លោក វ៉ាត សុម៉ៅ, កញ្ញា Sara ERJAVEC, លោក ហ៊ូ ជីសេង |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៥ | ចាប់ផ្ដើមម៉ោង៖ ០៩.០៩ | បញ្ចប់ម៉ោង៖ ១១.៣០ |
| សម្រាកពេលព្រឹក | ចាប់ផ្ដើមម៉ោង៖ ១០.១១ | បញ្ចប់ម៉ោង៖ ១០.៣៥ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០១ ម៉ោង និង ៥៦ នាទី |

**កិច្ចដំណើរការនីតិវិធីផ្សេងទៀត**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ០៩.០៩ | ០៩.១២ |
| សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើការនីតិវិធីពីបន្ទប់ឃុំខ្លួនក្រោមសាលសវនាការ | មេធាវីការពារក្ដី នួន ជា | ០៩.១២ | ០៩.១៤ |
| ការតាំងសំណួរទៅកាន់សាក្សី រៀល សន (2-TCW-860) | មេធាវីការពារក្ដី ខៀវ សំផន | ០៩.១៥ | ១១.០៤ |
| ការផ្លាស់ប្ដូរកាលបរិច្ឆេទនៃការស្ដាប់សក្ខីកម្មសាក្សី 2-TCW-822 | អង្គជំនុំជម្រះ | ១០.៣៦ | ១០.៣៨ |
| ការស្នើសុំឱ្យធ្វើសវនាការស្ដាប់សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីថ្មី និងការស្នើសុំឱ្យទទួលយកភស្តុតាងថ្មី | អង្គជំនុំជម្រះ<br><br>សហមេធាវីនាំមុខ<br><br>សហព្រះរាជអាជ្ញា<br>មេធាវីការពារក្ដី នួន ជា<br>មេធាវីការពារក្ដី ខៀវ សំផន | ១១.០៦<br>១១.១៧<br>១១.០៧<br>១១.១២<br>១១.០៩<br>១១.១០<br>១១.១២ | ១១.០៧<br>១១.១៧<br>១១.០៩<br>១១.១៤<br>១១.១០<br>១១.១២<br>១១.១២ |

| | | | |
|---|---|---|---|
| សេចក្តីសម្រេចលើសំណើសុំផ្អាកសវនាការដោយសារឯកសារដាក់បង្ហាញពីសំណុំរឿង ០០៣ និង ០០៤ | អង្គជំនុំជម្រះ | ១១.១៧ | ១១.២២ |
| ការប្រកាសផ្អាកសវនាការ | អង្គជំនុំជម្រះ | ១១.២៩ | ១១.៣០ |

**<u>សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

**<u>ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី</u>**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីរាយការណ៍ថា គ្រប់ភាគីទាំងអស់មានវត្តមាន។ ជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួន ក្រោមសាលសវនាការ។

**<u>សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើការនីតិវិធីពីបន្ទប់ឃុំខ្លួនក្រោមសាលសវនាការ</u>**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ក្នុងសាលសវនាការ និងអនុញ្ញាតឱ្យគាត់តាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួន ស្ថិតនៅខាងក្រោមសាលសវនាការ។

**<u>ការតាំងសំណួរទៅកាន់សាក្សី រៀល សន (2-TCW-860)</u>**

មេធាវីការពារក្តី ខៀវ សំផន បានបន្តការតាំងសំណួរទៅកាន់សាក្សី រៀល សន ហើយការស្តាប់សក្ខីកម្មសាក្សីរូបនេះត្រូវបានបញ្ចប់។ មេធាវីប្រឹក្សារបស់សាក្សី មានវត្តមាននៅក្នុងបន្ទប់សវនាការ។

**<u>ការផ្លាស់ប្តូរកាលបរិច្ឆេទនៃការស្តាប់សក្ខីកម្មរបស់សាក្សី (2-TCW-822)</u>**

អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីថា អង្គជំនុំជម្រះនឹងមិនធ្វើសវនាការស្តាប់សក្ខីកម្មរបស់សាក្សីបម្រុង 2-TCW-822 នៅថ្ងៃនេះនោះទេ ដោយសារតែសាក្សីរូបនេះមានបញ្ហាសុខភាព។ សវនាការស្តាប់សក្ខីកម្មសាក្សីរូបនេះ នឹងធ្វើឡើងក្នុងពេលសមស្របខាងមុខ។

**<u>ការស្នើសុំឱ្យធ្វើសវនាការស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីថ្មី និងស្នើសុំឱ្យទទួលយកភស្តុតាងថ្មី</u>**

អង្គជំនុំជម្រះបានស្តាប់សេចក្តីសន្និដ្ឋានផ្ទាល់មាត់របស់ភាគី ពាក់ព័ន្ធនឹងសំណើរបស់សហមេធាវីនាំមុខ ដែលបានស្នើសុំឱ្យអង្គជំនុំជម្រះស្តាប់នូវសក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីថ្មី ដោយរួមទាំងសុំឱ្យទទួលយកនូវឯកសារថ្មីដែលពាក់ព័ន្ធជាមួយនឹងសំណើសុំនេះផងដែរ (E344 និង E344.1) ។ សហព្រះរាជអាជ្ញាបានធ្វើការគាំទ្រទៅលើសំណើនេះ។ មេធាវីការពារក្តី នួន ជា ពុំបានបដិសេធទៅនឹងសំណើនេះទេ ប៉ុន្តែបានបង្ហាញថាសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីនេះគឺមិនមានភាពពាក់ព័ន្ធនោះទេ។ មេធាវី

ការពារក្តី ខៀវ សំផន ក៏ពុំបានបដិសេធទៅនឹងសំណើនេះដែរ ដោយឡែកបានលើកឡើងថាសំណើនេះមានភាពយឺតយាវ និង ថាដើមបណ្តឹងរដ្ឋប្បវេណីមិនអាចជឿជាក់បានទេដោយសារគាត់មានបញ្ហាផ្នែកស្មារតីផងដែរ។ អង្គជំនុំជម្រះបានជូនដំណឹងទៅភាគីថានឹងមានសេចក្តីសម្រេចលើបញ្ហានេះនាពេលឆាប់ៗខាងមុខ។

**<u>សេចក្តីសម្រេចលើសំណើសុំផ្អាកសវនាការដោយសារឯកសារដាក់បង្ហាញពីសំណុំរឿង ០០៣ និង ០០៤</u>**

អង្គជំនុំជម្រះបានធ្វើសេចក្តីសម្រេចផ្ទាល់មាត់លើសំណើសុំឲ្យមានការផ្អាកសវនាការពី មេធាវីការពារក្តី នួន ជា (សូមមើល E319/16, T. 4 March 2015, T. 5 March 2015) ហើយបានប្រកាសថានឹងផ្អាកកិច្ចដំណើរការនីតិវិធីសវនាការចាប់ពីថ្ងៃទី ០៦ រហូតដល់ ថ្ងៃទី ០៩ ខែមេសា ហើយនឹងចាប់ផ្តើមធ្វើសវនាការឡើងវិញបន្ទាប់ពីការឈប់សម្រាកចូលឆ្នាំខ្មែរ ដើម្បីផ្តល់ឱកាសឲ្យភាគីមានពេលវេលាគ្រប់គ្រាន់ក្នុងការពិនិត្យឯកសារដែលបានដាក់បង្ហាញ។

**<u>កាលបរិច្ឆេទនៃការស្តាប់សក្ខីកម្មសាក្សីបន្ទាប់</u>**

អង្គជំនុំជម្រះប្រកាសថានឹងជូនដំណឹងទៅភាគីតាមរយៈអ៊ីមែល អំពីលំដាប់លំដោយសាក្សីបន្ទាប់ និងអំពីសវនាការនៅថ្ងៃ ចន្ទ ទី ២៣ ខែ មីនា ឆ្នាំ ២០១៥។

**<u>កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង</u>**

Reclassified

| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/5511 | | 00402497-<br>00402504<br>00412169-<br>00412175<br>00434507-<br>00434513 | Written Record of Interview of RIEL San | P | 00402498<br>00402504 | 00412171<br>00412175 | 00434508<br>00434513 |

Other documents (No Change)

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E319.1.2<br>1 | | 00975621<br>-<br>00975646<br>00982633<br>-<br>00982663<br>00980616 | Written record of Witness interview of [REDACTED] | SC | 00975628<br>00975629 | 00982641<br>00982643 | 00980622<br>00980624 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | -<br>00980640 | | | | | |
| E3/5859 | | 00418807<br>-<br>00418889<br>00729022<br>-<br>00729109<br>00808602<br>-<br>00808693 | DC-Cam interview with RIEL Sorn on 22nd May 2001 | P | 00418835<br>00418832<br>00418833 | 00729051<br>00729049 | 00808632 |

**<u>ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖</u>**

- អនុញ្ញាតឱ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីតាមដានសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។
- សម្រេចផ្អាកកិច្ចដំណើរការនីតិវិធីសវនាការដើម្បីឱ្យភាគីមានពេលវេលាគ្រប់គ្រាន់ក្នុងការពិនិត្យមើលឯកសារដែលបានដាក់បង្ហាញពីសំណុំរឿង ០០៣ និង ០០៤។
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ត្រឡប់ទៅមន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនគាត់ មកសាលសវនាការវិញឱ្យបានមុនម៉ោង ០៩.០០ ព្រឹក នៅថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១៥ ។

**<u>កាលវេលាសវនាការបន្ត</u>**

សវនាការនឹងបន្តទៅថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១៥ ចាប់ផ្តើមពីម៉ោង ០៩.០០ ព្រឹក។

ភ្នំពេញ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៥

ក្រឡាបញ្ជី ក្រឡាបញ្ជី

**ជា ស៊ុនហ៊ង** **Maddalena GHEZZI**